ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងពិធីបើកកិច្ចប្រជុំទ្វេភាគីរវាង ធនាគារជាតិនៃកម្ពុជានិងធនាគារកណ្តាលថៃ
## នៅខេត្តសៀមរាប ថ្ងៃទី៨ ខែមីនា ឆ្នាំ២០១៤

សូមគោរព ៖

- ឯកឧត្តម Prasarn Trairatvorakul ទេសាភិបាលធនាគារកណ្តាលថៃ ជាទីគោរពរាប់អាន!
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងសមាជិកគណៈប្រតិភូទាំងអស់ជាទីស្នេហា!

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាទីបំផុត ដោយធនាគារជាតិនៃកម្ពុជាមានកិត្តិយស បានរៀបចំកិច្ចប្រជុំសហប្រតិបត្តិការទ្វេភាគី រវាងធនាគារជាតិនៃកម្ពុជានិងធនាគារកណ្តាលថៃ ដែលជាអតីតរាជធានីបុរាណ និងជាទីក្រុងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ។ ខ្ញុំសង្ឃឹមថាក្នុងដំណើរទស្សនកិច្ចនេះ ឯកឧត្តម ទេសាភិបាល និងគណៈប្រតិភូនឹងបានស្វែងយល់បន្ថែមទៀតអំពីវប្បធម៌ អរិយធម៌ និងប្រពៃណីខ្មែរដែលមានតាំងពីយូរលង់ណាស់មកហើយ ។

ជាថ្មីម្តងទៀត ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះ ឯកឧត្តម ទេសាភិបាល និងគណៈប្រតិភូធនាគារកណ្តាលថៃ ដែលអញ្ជើញមកបំពេញទស្សនៈកិច្ច និងចូលរួមកិច្ចប្រជុំនៅពេលនេះ ។ កិច្ចប្រជុំនេះ មានសារៈសំខាន់ណាស់សម្រាប់មន្ត្រីបុគ្គលិករបស់ធនាគារកណ្តាលយើងទាំងពីរប្រជុំដើម្បីផ្លាស់ប្តូរយោបល់និងបទពិសោធន៍គ្នាលើផ្នែកជំនាញនៃវិស័យធនាគារ ។ កិច្ចប្រជុំនេះ ក៏ជាវេទិកាដើម្បីពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការមិត្តភាពសាមគ្គីភាពជាប្រពៃណី ក្នុងនាមប្រទេសជិតខាងល្អនិងបានបម្រើប្រយោជន៍រួមដល់ប្រជាជននៃប្រទេសយើងទាំងពីរ ផងដែរ ។ តាមរយៈកិច្ចប្រជុំនេះ ស្ថាប័នរបស់យើងទាំងពីរនឹងបន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការឱ្យកាន់តែប្រសើរ និងជិតស្និទ្ធថែមទៀត ។

- ឯកឧត្តម ទេសាភិបាល
- ឯកឧត្តម លោកជំទាវ លោក លោកស្រី និងសមាជិកគណៈប្រតិភូ ជាទីមេត្រី

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបជូនដោយសង្ខេបពីវឌ្ឍនភាពនៃសេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះថា សេដ្ឋកិច្ចកម្ពុជាបានបន្តអភិវឌ្ឍយ៉ាងឆាប់រហ័សប្រកបដោយភាពរឹងមាំ ហើយក្នុងឆ្នាំ២០១៣ កម្ពុជាសម្រេចបានអត្រាកំណើន ៧,៥% ដែលគាំទ្រជាចម្បងដោយការរីកចម្រើននៃវិស័យកសិកម្ម ការនាំចេញសម្លៀកបំពាក់ ទេសចរណ៍ និងសំណង់ ។


ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ជាមួយភាពអំណោយផលផ្នែកសេដ្ឋកិច្ច គួបផ្សំនឹងផែនការអភិវឌ្ឍវិស័យហិរញ្ញវត្ថុច្បាស់លាស់ វិស័យធនាគារនៅកម្ពុជាបានបន្តអភិវឌ្ឍយ៉ាងរហ័ស ទាំងវិសាលភាព ទំហំប្រតិបត្តិការ ផលិតផល និងសេវាហិរញ្ញវត្ថុ ដែលបានរួមចំណែកកាន់តែសកម្មក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ បច្ចុប្បន្ន ទ្រព្យសកម្មនៃវិស័យធនាគារបានកើនឡើងដល់ ៨៥% នៃផ.ស.ស ឥណទានចំពោះវិស័យឯកជនកើនដល់ ៥៥% និងប្រាក់បញ្ញើបានកើនដល់ ៥៦% នៃផ.ស.ស ។ ទន្ទឹមនេះ វិស័យនេះកំពុងត្រូវបានធ្វើទំនើបកម្មជាលំដាប់ តាមរយៈការពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិ សមត្ថភាពត្រួតពិនិត្យធនាគារ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធវិស័យហិរញ្ញវត្ថុ ។ ចំពោះវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា ក៏បាននិងកំពុងរីកចម្រើនគួរឱ្យកត់សម្គាល់ និងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់សេវាហិរញ្ញវត្ថុជូនប្រជាជនរហូតដល់ជនបទ ដែលបានរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជននិងកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

ចំពោះវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការទ្វេភាគី ជានិច្ចកាល រដ្ឋាភិបាលនៃប្រទេសទាំងពីរតែងតែបានលើកកម្ពស់ទំនាក់ទំនងមិត្តភាពជាប្រពៃណី និងកិច្ចសហប្រតិបត្តិការបច្ចេកទេសទាំងក្នុងក្របខ័ណ្ឌជាតិនិងថ្នាក់ស្ថាប័ន ។ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាទីបំផុត ដោយឃើញកិច្ចសហប្រតិបត្តិការរបស់យើងកាន់តែមានការវិវត្តរីកចម្រើនជាបន្តបន្ទាប់យ៉ាងឆាប់រហ័ស ជាពិសេសបន្ទាប់ពីមានការចុះអនុស្សរណៈយល់គ្នាកន្លងមក ។ បច្ចុប្បន្នកិច្ចសហប្រតិបត្តិការរបស់យើងត្រូវបានពង្រឹងនិងពង្រីកលើគ្រប់ផ្នែកសំខាន់ៗនៃប្រតិបត្តិការធនាគារកណ្តាលទាំងពីរដូចជា ការផ្លាស់ប្តូរព័ត៌មាន និងការអភិវឌ្ឍធនធានមនុស្សតាមរយៈការសិក្សាស្រាវជ្រាវរួមគ្នា សិក្ខាសាលា កិច្ចប្រជុំ និងទស្សនកិច្ចសិក្សារវាងស្ថាប័នទាំងពីរ ។

**- ឯកឧត្តម ទេសាភិបាល**

**- ឯកឧត្តម លោកជំទាវ លោក លោកស្រី និងសមាជិកគណៈប្រតិភូ ជាទីមេត្រី**

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ស្ថាប័នរបស់យើងទាំងពីរនឹងបន្តលើកកម្ពស់កិច្ចសហ-ប្រតិបត្តិការឱ្យកាន់តែជិតស្និទ្ធថែមទៀត ហើយអង្គប្រជុំនៅថ្ងៃនេះ សរបញ្ជាក់ពីឆន្ទៈនៃការបន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការរបស់ស្ថាប័នយើងទាំងពីរ ។ ដើម្បីឱ្យអង្គប្រជុំជ្រាបបន្ថែមទៀតពីការអភិវឌ្ឍរីកចម្រើនថ្មីៗនៃសេដ្ឋកិច្ចកម្ពុជា និងវិស័យធនាគារនៅកម្ពុជាបន្ថែមទៀត ខ្ញុំសូមឱ្យ ឯកឧត្តម គិម វ៉ាដា អគ្គនាយកត្រួតពិនិត្យ និងលោក ឃូ វុឌ្ឍី ប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ ធ្វើបទឧទ្ទេសនាមជូនអង្គប្រជុំនាពេលបន្តិចទៀតនេះ ។

ខ្ញុំសូមឱ្យកិច្ចប្រជុំនាពេលនេះប្រព្រឹត្តទៅក្នុងបរិយាកាសរីករាយនិងស្និទ្ធស្នាលជាទីបំផុត ព្រមទាំងទទួលបាននូវផ្លែផ្កា ។

**សូមអរគុណ!**